ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

CAMBODIATRADE

EIF

# សេចក្តីប្រកាសស្តីពី
# ការណែនាំពីរបៀបចុះឈ្មោះ
# លើផ្សារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក CambodiaTrade

CambodiaTrade គឺជាផ្សារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (e-commerce marketplace) ដែលប្រតិបត្តិការតាមរយៈគេហទំព័រ CambodiaTrade.com ក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម ក្នុងគោលបំណងជួយដល់សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជាក្នុងការលក់ផលិតផលតាមប្រព័ន្ធអនឡាញដល់អតិថិជនសក្តានុពលទាំងក្នុងស្រុក និងទីផ្សារក្រៅស្រុក។ ផ្សារនេះត្រូវបានបង្កើតឡើងដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម (Enhanced Integrated Framework) ក្រោមគម្រោងអភិវឌ្ឍន៍ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា (Go4eCAM) ដែលមានគោលបំណងសំខាន់ក្នុងការជំរុញឱ្យទទួលបានអត្ថប្រយោជន៍ពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់សហគ្រាសធុនតូចនិងមធ្យម។

បច្ចុប្បន្ននេះ ផ្សារត្រូវបានបើកសម្រាប់ការចុះឈ្មោះជាមុនទៅដល់សហគ្រាសធុនតូចនិងមធ្យម ដែលមានបំណងចង់លក់ផលិតផលនៅលើផ្សារនេះ។ ដើម្បីអាចយល់ពីរបៀបចុះឈ្មោះបង្កើតគណនីជាអាជីវករបាននៅក្នុងផ្សារ CambodiaTrade សូមលោកអ្នកស្វែងរកការណែនាំពីរបៀបចុះឈ្មោះនៅក្នុងគេហទំព័រ CambodiaTrade.com ឬតាមរយៈ QR កូដ ឬតំណរលីងដូចខាងក្រោម៖

https://drive.google.com/drive/folders/1qCNKL245XJGNqK0hVTQmDNJOfpmSszgm?usp=sharing

នៅពេលដែលការចុះឈ្មោះរបស់លោកអ្នកត្រូវបានអនុម័ត សហគ្រាសធុនតូចនិងមធ្យមអាចបំពេញស្តុករបស់ខ្លួនដោយបង្ហោះផលិតផលរបស់ពួកគេនៅលើទំព័រហាងរបស់ខ្លួន[1]។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការចុះឈ្មោះជាមុន និងផ្សារ CambodiaTrade សូមលោកអ្នកចូលទៅមើលគេហទំព័រ CambodiaTrade.com ឬទំព័រ Facebook.com/cambodiatrade.co ឬផ្ញើអ៊ីមែលទៅ info@cambodiatrade.com។

ថ្ងៃចន្ទ ៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១

[1] ដើម្បីប្រើទីផ្សារបាន សហគ្រាសធុនតូច និងមធ្យមត្រូវតែយល់ព្រមនឹងលក្ខន្តិកៈ និងគោលការណ៍ឯកជនភាពនៃទីផ្សារដែលមាននៅលើទំព័រចុះឈ្មោះ។ សហគ្រាសធុនតូចនិងមធ្យមត្រូវបានលើកទឹកចិត្តឱ្យអានលក្ខន្តិកៈ និងគោលការណ៍ឯកជនភាពដោយយកចិត្តទុកដាក់។

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Fax: (855) 23 866 469

**KINGDOM OF CAMBODIA**
**NATION RELIGION KING**

MINISTRY OF COMMERCE

CAMBODIATRADE

EIF

### Announcement
### "Guidelines for Pre-Registration" in CambodiaTrade

**CambodiaTrade** is an e-commerce marketplace, located at **CambodiaTrade.com,** operated by the Ministry of Commerce of Cambodia to serve Cambodia's small and medium enterprises to sell their products online to potential clients in the domestic and cross-border markets. The marketplace is developed with financial support from the **Enhanced Integrated Framework** under the Go4eCAM project with the main objective in realizing the benefits of e-commerce for the SMEs.

The marketplace is now open for pre-registration by SMEs who wish to sell products on the marketplace. To be able to fully understand how to register for an account as vendors with CambodiaTrade, please find a "Guidelines for Pre-Registration" at **CambodiaTrade.com** or the QR Code or link below:

https://drive.google.com/drive/folders/1qCNKL245XJGNqK0hVTQmDNJOfpmSszgm?usp=sharing

Once the registrations have been approved, SMEs would be able to fill in their inventory by posting their products on to their stores[1]. For additional information on the pre-registration and the marketplace, please visit **CambodiaTrade.com** or the Facebook page at **Facebook.com/cambodiatrade.co** or send email to: info@cambodiatrade.com.

Phnom Penh, 14 June 2021

[1] To use the marketplace, SMEs have to agree to the Terms and Conditions and Privacy Policy of the marketplace available on the registration page. SMEs are encouraged to read the Terms and Conditions and Privacy Policy carefully.

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្សី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារៈ (៨៥៥) ២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Fax: (855) 23 866 469